**សេចក្តីផ្តើម:** *គំរោង* ***Papussa*** *សូមស្វាគមន៍ : ជាគំរោងដែលផ្តល់មូលនិធិដោយសហគមន៍ អឺរ៉ុប ដើម្បីសិក្សានិងបង្ហាញអំពីស្ថានភាព សារសំខាន់ និងផលប៉ះពាល់ នៃការចិញ្ចឹមត្រី និងដាំដុះបន្លែ ជលផល ឬបន្លែទឹកនៅក្នុងទីក្រុងចំនួន ៤ នៃតំបន់អាស៊ីអគ្នេយ៍ ។*

**ឌីវីឌី** (DVD) នេះគឺជាសមិទ្ធផលរបស់គំរោងដែលបានអនុវត្តរួមគ្នាក្នុងរយៈពេល ៣ ឆ្នាំកន្លះ (ចាប់ពីខែមករា ឆ្នាំ២០០៣ ដល់ ខែមិថុនា ឆ្នាំ២០០៦) រវាងភាគីក្នុងតំបន់អាស៊ីអគ្នេយ៍ ជាមួយនឹងអឺរ៉ុប នាទីក្រុង បាងកក ហូជីមិញ ហាណូយ និង ភ្នំពេញ។ ឌីវីឌីនេះបង្ហាញជូននូវរាល់សមិទ្ធិផល និង លទ្ធផល ស្រាវជ្រាវរបស់គំរោង តាមរយៈរបាយការណ៍ អត្ថបទណែនាំបច្ចេកទេស ឯកសារផ្សេងៗ រួមទាំង ខ្សែវិដេអូ ប៉ូស្ទ័រ និងរូបថតជាច្រើនទៀត។ វាគួរតែត្រូវបានចាត់ទុកថា ជាឱកាសពិសេសមួយ ក្នុងការផ្សារភ្ជាប់ ទស្សនិយភាពនៃការងារអភិវឌ្ឍន៍ទីក្រុងដ៏មានសារសំខាន់តែត្រូវបានគេស្គាល់តិចតួចនោះ ទៅនឹង សកម្មភាព សក្តានុពលទាំងឡាយ ដែលម្ខាងអនុវត្តដោយអ្នកធ្វើគោលនយោបាយ និងម្ខាងទៀតអនុវត្តដោយកសិករ សហគមន៍និងអ្នកផ្សព្វផ្សាយ។ ឌីវីឌីនេះនឹងត្រូវបានប្រើជាមធ្យោបាយមួយក្នុងការស្វែងយល់នូវ ការពុះពារ របស់ប្រព័ន្ធផលិតកម្មទាំងឡាយនៅជាយក្រុង យុទ្ធសាស្ត្រសំខាន់ៗ រួមជាមួយឧទាហរណ៍ក្នុងការកំនត់រក បញ្ហានិងកាលានុវត្តភាព ព្រមទាំងផ្តល់ជាមគ្គុទេសដល់សារធារណជនគ្រប់ប្រភេទ វាមិនគ្រាន់តែបង្កើន ចំណេះដឹងរបស់គេប៉ុណ្ណោះទេ តែក៏ផ្តល់ជាអនុសាសន៍និងស្វែងរកចំលើយផងដែរ បង្កើនឱកាសអោយមាន ការដោះស្រាយដោយមាននិរន្តភាព។

**ឌីវីឌី** នេះត្រូវបានផលិតឡើងសំរាប់អ្នកប្រើប្រាស់ ក្នុងការរុករក និងទទួលបានពតិមាន តាម រយៈលក្ខខ័ណ្ឌ និង ការតភ្ជាប់ (Criteria and link) ដូចតទៅ:

- ចំណងជើងមេ បែងចែកឯកសារជា សេចក្តីផ្តើម អត្ថបទបោះពុម្ព វិដេអូ រូបថត ទំនាក់ទំនង ។ល។
- ដ្យាក្រាមរបស់គំរោងដែលអាចអោយអ្នកប្រើប្រាស់ ចូលទៅកាន់ពតិមានតាមលំដាប់លំដោយ
- រូបភាពទង់ជាតិ ខ្មែរ វៀតណាម និងថៃ ភ្ជាប់ទៅកាន់ អត្ថបទបោះពុម្ពទាំងឡាយជាភាសាខ្មែរ
- ផែនទី ចំនួន ២ ភ្ជាប់ទៅកាន់ លទ្ធផលដែលជាសមិទ្ធិផលរបស់ ស្ថាប័ននិមួយៗដែលជាភាគីគំរោង
- បើអ្នកប្រើប្រាស់អាចភ្ជាប់ទៅកាន់ អ៊ីនធើណេត នោះគេអាចចុចលើប៊ូតុងភ្ជាប់ទាំងឡាយ ដើម្បី ចូលទៅកាន់គេហទំព័រផ្សេងៗដែលទាក់ទងទៅនឹងការងាររបស់គំរោង។

*សូមកត់សំគាល់ថា* នៅពេលឌីវីឌីនេះត្រូវបានផលិតឡើង លទ្ធផលមួយចំនួនទៀតរបស់គំរោង មិនទាន់បានរួចរាល់នៅឡើយ តែលោកអ្នកអាចស្វែងរកវាបាននៅពេលដ៏ខ្លីខាងមុខនេះ នៅក្នុងគេហទំព័ររបស់គំរោង ដែលមានអស័យដ្ឋាន www.papussa.org

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ផ្នែកអភិវឌ្ឍន៏អន្តរជាតិរបស់ចក្រភពអង់គ្លេស (DFID) និង ក្រុមប្រឹក្សាចក្រភពអង់គ្លេស សំរាប់ការឧបត្ថម្ភគាំទ្រដល់គំរោងនេះរហូតមក និង សូមកត់សំគាល់ថា ទស្សនៈទាំងឡាយដែលឆ្លុះបញ្ចាំងនៅក្នុងឌីវីឌីនេះ មិនមែនជារបស់អង្គការមូលនិធិទាំងនោះទេ។ ជាចុងបញ្ចប់ យើងខ្ញុំសូមអរគុណ និងឧទ្ទិសកំរងឯកសារឌីវីឌីនេះ ដល់អ្នកចិញ្ចឹមត្រី និង អ្នកដាំដុះដំណាំបន្លែជលផលទាំងឡាយនៅក្នុងទីក្រុងទាំង ៤ របស់គំរោងដែលបានចំនាយពេលវេលា និង ចូលរួមចំណែករំលែកបទពិសោធន៏ធ្វើអោយគំរោងអាចដំណើរការទៅបាន ដែលក្នុងខណៈនេះដែរ ពួកគាត់កំពុងផលិតអាហារព្រមទាំងចូលរួមកែច្នៃឡើងវិញទឹកសំណល់ និងជួយថែរក្សាបរិស្ថានបៃតងសំរាប់អ្នករស់នៅរាប់លាននាក់នៅក្នុងទីក្រុងទាំងនោះ។